**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ........✓............ន. គ. ស/ស.ជ.លា.

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃអង្គារ ៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០២៤

## សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់ពេលវេលាបន្ថែម ក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលរងសវនកម្មឯករាជ្យ មកនិយ័តករគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.)** សូមជម្រាបជូនម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ(អង្គភាព)ឱ្យបានជ្រាបថា: សម្រាប់សហគ្រាស និងអង្គភាពរងសវនកម្មឯករាជ្យ កាលបរិច្ឆេទនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** នឹងត្រូវផុតកំណត់នៅ ***ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤*** ខាងមុខនេះ។ ដើម្បីសម្រួលដល់សហគ្រាស និងអង្គភាព ដែលរងសវនកម្មឯករាជ្យមួយចំនួន ដែលមិនទាន់បញ្ចប់នីតិវិធីជាស្ថាពរ **ន.គ.ស.** បានសម្រេចផ្តល់ពេលបន្ថែមចំនួន៣០(សាមសិប)ថ្ងៃ ក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ (E-Filing System) និងអនុញ្ញាតឱ្យដាក់លិខិតពន្យារពេលដូចខាងក្រោម÷

១. សហគ្រាស និងអង្គភាព រងសវនម្មឯករាជ្យ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** មិនឱ្យហួស ***ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤*** ។ សហគ្រាស និងអង្គភាព រងសវនម្មឯករាជ្យ ដែលបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មក **ន.គ.ស.** មិនឱ្យហួសរយៈពេល ***៧ ខែ បូក ២០ថ្ងៃ*** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

២. សហគ្រាស និងអង្គភាពអាចដាក់លិខិតស្នើសុំពន្យារពេលការបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ មក **ន.គ.ស.** មិនឱ្យហួស ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ ដោយត្រូវបង់កម្រៃសេវាសាធារណៈស្របតាមប្រកាសលេខ ០០១ អ.ស.ហ. ប្រក. ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមន្ត្រី **ន.គ.ស.** តាមរយៈលេខទូរសព្ទ និងតេឡេក្រាមដូចខាងក្រោម÷

- លោក ហាក់ សីហា ÷ **០៩៦ ៩ ១៩៩ ៩៩៨** សម្រាប់សហគ្រាស
- លោក យាន ផល្លា ÷ **០៨១ ៦៤៤ ៦៦៣** សម្រាប់អង្គភាព

**និយ័តករគណនេយ្យនិងសវនកម្ម** សង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនេះ ម្ចាស់សហគ្រាស និងអង្គភាព រងសវនកម្មឯករាជ្យទាំងអស់ នឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចគណនេយ្យនិងសវនកម្មបានទាន់ពេលវេលា តាមកាលកំណត់ប្រកបដោយការទទួលខុសត្រូវខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.

គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh

ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111